**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ២៤០៣ អយក.ហវ

ថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២២

**ជម្រាបជូន**
**-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង**
**-ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទក្រសួង**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3) លើមុខងារវិភាជន៍ថវិកា(BA) បញ្ជាទិញ(PO) គណនីត្រូវសង(AP) និងរបាយការណ៍ជូនអង្គភាពថវិកានៅរដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង ៖** ផែនការសកម្មភាពប្រចាំឆ្នាំ២០២២របស់នាយកដ្ឋានហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ជ្រាបថា៖ ក្រសួង បានកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣(EFMS V3) លើមុខងារវិភាជន៍ថវិកា(BA) បញ្ជាទិញ(PO) គណនីត្រូវសង(AP) និងរបាយការណ៍ដែលមានលក្ខណៈជា Web Application (Online) ក្នុងគោលបំណងបង្កើនស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបបច្ចេកវិទ្យា ព្រមទាំងស្របទៅនឹងការវិវត្តរបស់សង្គមនិងសេដ្ឋកិច្ចឌីជីថលបច្ចុប្បន្ន ជាពិសេសប្រព័ន្ធមានសមត្ថភាពក្នុងការពិនិត្យស្ថានភាពនៃការអនុវត្តថវិកា តាមដានការអនុវត្តផែនការសកម្មភាព និងផលិតរបាយការណ៍ហិរញ្ញវត្ថុនិងគណនេយ្យប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងស្របតាមគោលការណ៍ច្បាប់គតិយុត្ត។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3)លើមុខងារវិភាជន៍ថវិកា(BA) បញ្ជាទិញ(PO) គណនីត្រូវសង(AP) និងរបាយការណ៍ជូនអង្គភាពថវិការដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសម្រាប់ប្រើប្រាស់ចាប់ពីឆ្នាំ២០២២ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
 " ដើម្បីជ្រាបជាព័ត៌មាន "
- កាលប្បវត្តិ
- ឯកសារ .នា. ហិរញ្ញវត្ថុ